សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន
១២ កញ្ញា ២០១៤

**សូមគោរព ឯកឧត្តម អ៊ុំ ភូមិរ៉ូ អគ្គនាយករងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា** (CMAC)!
**សូមគោរព លោក ស៊ីមម្យូ ស៊ុស៊ុមឺ ប្រធានតំណាងអង្គការសកម្មភាពកំចាត់មីនជប៉ុន** (JMAS)!
**សូមគោរព អស់លោក លោកស្រី!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខានៅថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយជាមួយ អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS) សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនគឺ “គម្រោងបង្កើនសមត្ថភាពបោសសម្អាតមីន” សម្រាប់ CMAC ។

ដូចដែលយើងទាំងអស់គ្នាបានដឹងហើយ ដោយសារសង្គ្រាមផ្ទៃក្នុងជាច្រើនឆ្នាំ កម្ពុជានៅមានគ្រាប់មីនជាច្រើនដែលត្រូវបានកប់ចោលនៅក្នុងដី ពិសេសនៅភាគពាយ័ព្យនៃប្រទេស។ វត្តមាននៃគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះគឺជាឧបសគ្គដ៏ធំមួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា ហើយការដោះស្រាយបញ្ហាមីននេះគឺជាជំហានមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ច ក៏ដូចជាវិស័យកសិកម្ម និងការអភិវឌ្ឍជនបទផងដែរ។

រដ្ឋាភិបាលជប៉ុនបាននិងកំពុងបន្តឧបត្ថម្ភគាំទ្រដល់សកម្មភាពកំចាត់មីននៅកម្ពុជាតាមរយៈជំនួយឧបត្ថម្ភ ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្ទេរបច្ចេកទេស។ យ៉ាងណាមិញ បើទោះជាចំនួនជនរងគ្រោះបានបន្តថយចុះ ក៏នៅតែមានប្រជាជន១១១នាក់រងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណមិនទាន់ផ្ទុះក្នុងឆ្នាំ២០១៣ ជាពិសេសខេត្តបាត់ដំបងគឺជាតំបន់ដែលទទួលផលប៉ះពាល់ខ្លាំងជាងគេនោះ មានជនរងគ្រោះច្រើនជាងគេនៃចំនួនជនរងគ្រោះទាំងអស់។ ដូច្នេះយើងនៅតែមានតំរូវការខ្ពស់សម្រាប់សកម្មភាពបោសសម្អាតមីនក្នុងខេត្តនេះ។

ស្ថិតក្រោមស្ថានភាពបែបនេះ អង្គការ JMAS តាមរយៈជំនួយឧបត្ថម្ភផ្លូវការរបស់ជប៉ុនសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានសហការជាមួយ CMAC ក្នុងកិច្ចបោសសម្អាតមីន ក្នុងឆ្នាំ២០០២ និងពង្រីកគោលដៅរបស់ខ្លួនជាបន្តបន្ទាប់រហូតដល់១៣ខេត្ត នៅពេលបច្ចុប្បន្ននេះ។ រយៈពេល១០ឆ្នាំកន្លងមកនេះ អង្គការ JMAS បានបន្តធ្វើសកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណមិនទាន់ផ្ទុះ ក៏ដូចជាផ្ទេរបច្ចេកទេសជាច្រើនទៅដល់ CMAC ដែលជាការចូលរួមចំណែកដ៏ធំធេងដល់ការកសាងសន្តិភាពក្នុងប្រទេសកម្ពុជា។

ជាមួយនឹងជំនួយប្រមាណ ៩២លានយ៉េន ដែលរដ្ឋាភិបាលជប៉ុន ផ្តល់ដល់អង្គការ JMAS នៅថ្ងៃនេះ ខ្ញុំបានដឹងថាអង្គការ JMAS នឹង ធ្វើសកម្មភាពថ្មីដើម្បីរៀបចំកម្មវិធីសិក្សាថ្មីមួយ "ការរួមបញ្ចូលគ្នាវគ្គហ្វឹកហ្វឺនបោសសំអាតមីន" ដើម្បីបង្រៀនអំពីវិធីដោះមីនប្រកបដោយប្រសិទ្ធិភាព ដោយរួមបញ្ចូលរវាងម៉ាស៊ីននិងកំលាំងមនុស្ស ដល់កងអនុសេនាតូចបោសសម្អាតមីនរបស់ CMAC នៅឃុំចែងមានជ័យ ក្នុងស្រុកបាណន់ ខេត្តបាត់ដំបង ដែលជាការហ្វឹកហ្វឺនជាក់ស្តែង ក្រោមជំនួយបច្ចេកទេសពីទីប្រឹក្សារបស់អង្គការ JMAS។ តាមរយៈការអនុវត្តគម្រោងនេះ ពួកគេនឹងអាចធ្វើការបោសសម្អាតមីនបានឆាប់រហ័សជាងមុន ដែលនឹងរួមចំណែកដល់ការសម្រេចតាមផែនការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងកាបោសសម្អាតមីនឲ្យអស់ត្រឹមឆ្នាំ២០១៩ដូចមានចែងក្នុងអនុសញ្ញាអូតាវ៉ា Otawa។

ជាងនេះទៅទៀត ខ្ញុំបានដឹងថា ជាផ្នែកមួយនៃការផ្ទេរបច្ចេកទេស កងអនុសេនាតូចមួយដែលទទួលបានការបណ្តុះបណ្តាលដោយ JMAS នៅក្នុងគម្រោងលើកមុននឹងត្រូវក្លាយជាកងអនុសេនាតូចគំរូ ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលកម្មវិធីសិក្សាថ្មីនេះ។ កងអនុសេនាតូចនេះរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់ដើម្បីរួមចំណែកដល់កិច្ចសហប្រតិបត្តិការត្បូង-ត្បូង ក៏ដូចជា កិច្ចសហប្រតិបត្តិការអន្តជាតិដទៃទៀត។

តាមរយៈគម្រោងនេះ ក្រៅពីការកសាងសមត្ថភាពដល់ CMAC ប្រជាពលរដ្ឋប្រមាណប្រាំពាន់ប្រាំបួនរយនាក់ក្នុងភូមិ៤នៃឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ក៏នឹងត្រូវបានរំដោះចេញពីការគំរាមកំហែង និងការភ័យខ្លាចដោយសារគ្រាប់មីន។ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងធ្វើឲ្យស្ថានភាពជីវិតរបស់ពួកគេមានលំនឹង ធ្វើឲ្យប្រសើរឡើងនូវបរិស្ថានរស់នៅ ក៏ដូចជាបន្តការអភិវឌ្ឍសហគមន៍ក្នុងតំបន់។

ជាចុងក្រោយនេះ ជំនួយឧបត្ថម្ភរបស់ជប៉ុនសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានផ្តល់ជូនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ ហើយខ្ញុំសូមធ្វើការកោតសរសើរ និងគោរពដោយស្មោះចំពោះលោកអ្នកទាំងអស់ដែលបានរួមចំណែកក្នុងកិច្ចការបោសសម្អាតមីននៅកម្ពុជាដែលជាកិច្ចការដ៏លំបាក និងប្រឈមនឹងគ្រោះថ្នាក់មួយ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់ប្រជាជនក្នុងតំបន់ប៉ុណ្ណោះទេ ហើយក៏នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជាផងដែរ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!